រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧

# សេចក្តីថ្លែងការណ៍

# ស្តីអំពី

# មន្ត្រីជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទត្រូវគោរពតាមគោលការណ៍អព្យាក្រឹត្យ ឥតលំអៀង និងផ្តល់កិច្ចសហការជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីសុវត្ថិភាពរបស់បេក្ខជន និងបេក្ខនារីគ្រប់គណបក្សនយោបាយ និងធានាដំណើរការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌

សមាគម និងអង្គការសង្គមស៊ីវិលនៅកម្ពុជា នៃបន្ទប់ស្ថានការណ៍សម្រាប់ការបោះឆ្នោត ស្វាគមន៍សេចក្តីណែនាំរួមរបស់ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប ) ដែលបានចេញកាលពី ថ្ងៃទី២៤ខែឧសភា ដើម្បីបញ្ជាទៅកាន់កម្លាំង អាជ្ញាធរ និងប្រដាប់អាវុធគ្រប់ប្រភេទហាមដាច់ខាតការយកកម្លាំងទៅគម្រាមកំហែងប្រជាពលរដ្ឋ ឬទៅបំភិតបំភ័យពលរដ្ឋ ដើម្បីរក្សាឲ្យបានសុខសន្តិភាព សុវត្ថិភាព និងស្ថេរភាពសង្គម និងចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

បន្ថែមលើសពីនេះទៀត សមាគម និងអង្គការសង្គមស៊ីវិលនៅកម្ពុជា នៃបន្ទប់ស្ថានការណ៍សម្រាប់ការបោះឆ្នោតឆ្នាំ២០១៧ ស្នើឲ្យ គ.ជ.ប ឬ/និងគណៈបញ្ជាការសន្តិសុខ អចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតចេញសេចក្តីរំលឹក ឬ ព្រមានចំពោះមន្ត្រីជាន់ខ្ពស់កងយោធពលខេមរភូមិន្ទណាមិនគោរពតាមក្រមសីលធម៌ បទបញ្ញានីតិវិធីរបស់គ.ជ.ប និងច្បាប់បោះឆ្នោត ក្រមសីលធម៌ និងច្បាប់ស្តីពីលក្ខន្តិកៈ សម្រាប់យោធិននៃកងយោធិននៃកងយោធពលខេមរភូមិន្ទ និង ដើម្បីបង្កបរិយាកាសអំណោយផល និងដោយគ្មានការភ័យខ្លាចដល់ប្រជាពលរដ្ឋទូទៅបានចូលរួមឲ្យបានពេញលេញក្នុងដំណើរការឃោសនាបោះឆ្នោត និងដល់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតទៅចូលរួមបោះឆ្នោតនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧។ ដូចជាករណី ក្នុងអំឡុងពេលបោះឆ្នោតមន្ត្រីជាន់ខ្ពស់កងយុទ្ធពលខេមរភូមិន្ទមានសេចក្តីថ្លែងការណ៍ ឬនិយាយថាឲ្យកងទ័ពត្រូវប្រឆាំងនឹងក្រុម ឬកំចាត់ចោលមនុស្ស និងគណបក្សប្រកួតប្រជែងណាមួយ ឬថាសង្គ្រាមនឹងកើតមានដោយសារការប្រែប្រួលលទ្ធផលចេញពីការបោះឆ្នោត ឬព្រមានបង្កហឹង្សាលើប្រជាពលរដ្ឋ ដែលមិនយល់ស្របនឹងការរៀបចំដំណើរការបោះឆ្នោត ឬលទ្ធផលនៃការបោះឆ្នោត។

សមាគម និងអង្គការសង្គមស៊ីវិលនៅកម្ពុជានៃបន្ទប់ស្ថានការណ៍សម្រាប់ការបោះឆ្នោតឆ្នាំ២០១៧ មានការព្រួយបារម្ភចំពោះការលើកឡើងរបស់អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ដែលបានបញ្ជាឲ្យកងទ័ព

ទាំងអស់ការពារ «សណ្តាប់ធ្នាប់សាធារណៈ» ... និងប្រយុទ្ធប្រឆាំងនឹង «បដិវត្តន៍ពណ៌»...[1] ដែលការលើកឡើងនេះនៅក្នុងអំឡុងពេលនៃយុទ្ធនាការឃោសនាបោះឆ្នោត។ យើងខ្ញុំយល់ឃើញថា អគ្គមេបញ្ជាការ មេបញ្ជាការ មន្ត្រីជាន់ខ្ពស់ និងកងទ័ពនៃកងយោធពលខេមរភូមិន្ទទាំងអស់ត្រូវគោរពក្រមសីលធម៌យោធិន នៃកងយោធពលខេមរភូមិន្ទ ពិសេសចំណុចទី៦ ចែងថា «*ហាមប្រើឥទ្ធិពលអំណាចនៃតួនាទី......ដូចជាការនិយាយដោយផ្ទាល់ ឬប្រយោលដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ...ដើម្បីបំភិតបំភ័យ ការលើកឡើងដោយផ្ទាល់មាត់ដោយយោងលើព្រឹត្តិការណ៍ពីអតីតកាល និងហាមជ្រៀតជ្រែកក្នុងកិច្ចប្រតិបត្តិបោះឆ្នោត*»។ ថ្នាក់ដឹកនាំទាំងអស់នៃកងយោធពលខេមរៈភូមិន្ទ ក៏ត្រូវគោរពគោលបំណងនៃផែនការអន្តរស្ថាប័ន ស្តីអំពីកិច្ចការពារការបោះឆ្នោត ដែលកងកម្លាំងប្រដាប់អាវុធត្រូវផ្តល់កិច្ចសហប្រតិបត្តិការជាមួយ គ.ជ.ប និងគោរពអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍ដូចមានចែងក្នុងច្បាប់នានា ជាពិសេសច្បាប់បោះឆ្នោត ព្រមទាំងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងត្រូវធានាសុវត្ថិភាពដល់បេក្ខជន/បេក្ខនារីមកពីគ្រប់គណបក្សនយោបាយចូលរួមប្រកួតប្រជែងក្នុងសម័យបោះឆ្នោតដោយរលូន និងគ្មានការភ័យខ្លាច ឬការបំភិតបំភ័យ ជាពិសេសត្រូវធានាដំណើរការបោះឆ្នោតមួយប្រកបដោយភាពសេរី ត្រឹមត្រូវ និងយុត្តិធម៌ស្របតាមស្មារតីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១។ យើងខ្ញុំស្វាគមន៍ចំពោះអនុក្រឹត្យស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត ផែនការអន្តរស្ថាប័ន និងកិច្ចការងារបោះឆ្នោត និងសេចក្តីណែនាំរបស់ គ.ជ.ប ស្តីពីកិច្ចសហការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤នេះ ដែលតម្រូវឲ្យស្ថាប័នពាក់ព័ន្ធទាំងឡាយត្រូវធានានូវ*បរិយាកាសល្អ អព្យាក្រឹត្យ និងយុត្តិធម៌*ក្នុងការបោះឆ្នោត។

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

| | | | |
|---|---|---|---|
| 1. | លោក គល់ បញ្ញា | នាយកប្រតិបត្តិ COMFREL | ០១២ ៩៤ ២០ ១៧ |
| 2. | លោក សំ គន្ធាមី | នាយកប្រតិបត្តិ NICFEC | ០១២ ៨២ ២២៧៣ |
| 3. | លោក ស៊ឹងសែន ករុណា | មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់ ADHOC | ០៨៩ ៦៦ ៦៣ ១២ |
| 4. | លោក ប៉ែន សុមុនី | ប្រធាន CVS | ០១២ ៧០ ៨០ ៩៣ |
| 5. | លោក ឱម សារ៉ាត | នាយកប្រតិបត្តិ FACT | ០១២ ៨៥ ៨៤ ២០ |
| 6. | លោកស្រី ធីតា ឃឹះ | នាយិកាប្រតិបត្តិ SILAKA | ០១២ ៨៣ ៨៤ ៦៤ |
| 7. | លោក យង់ គិមអេង | នាយកប្រតិបត្តិ PDP-Center | ០១៦ ៨២ ៨២ ១១ |

---

[1] វណ្ណ វើន, "អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទបញ្ជាឲ្យកងទ័ពប្រឆាំង 'បដិវត្តន៍ពណ៌'", **ខេមបូឌា ដេលី, (ថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០១៧) សូមចូលមើលតាមរយៈតំណនេះ** http://www.cambodiadailykhmer.com/37527

| | | |
|---|---|---|
| 8. លោកស្រី រស់សុភាព | នាយិកាប្រតិបត្តិ GADC | ០១២ ៦២ ៧៨ ៥៧ |
| 9. លោកស្រី ជឹម ចាន់នាង | អគ្គលេខាធិការ NGO CEDAW | ០១២ ៦៦ ៨៨ ៥៣ |
| 10. លោក មឿង តុលា | នាយកប្រតិបត្តិ Central | ០៩៣ ៥៥ ៦៦ ៤៣ |
| 11. លោក ថេង សារឿន | អគ្គលេខាធិការ CCFC | ០៧៨ ២២ ៥០ ៨៨ |
| 12. លោក ស ម៉ូរ៉ា | ប្រធានសហព័ន្ធ CFSWF | ០១៦ ៥២ ៥៧ ៨១ |
| 13. លោក សៅ កុសល | ប្រធានគ្រប់គ្រងកម្មវិធីបច្ចេកទេស STT | ០១៧ ៥៥ ៥៨ ៨៧ |
| 14. លោក ហួន ឈុនឌី | នាយកប្រតិបត្តិ CLEC | ០៩៣ ៣៤៥ ៦០២ |
| 15. លោក វន់ ពៅ | ប្រធានសមាគម IDEA | ០៩៣ ៦២ ៩២ ៩៨ |
| 16. លោក ង៉ាច សាមីន | អ្នកសម្របសម្រួលគម្រោង CIYA | ០៩៩ ៩៤ ៨៤ ៧៧ |
| 17. លោក សៀ ភារម្យ | នាយកប្រតិបត្តិ HRTF | ០១២ ៨៥ ២៣ ២៥ |
| 18. លោកស្រី ចក់ សុភាព | នាយិកាប្រតិបត្តិ CCHR | ០១១ ៩៤៣ ២១៣ |